# សង្គមស៊ីវិលចង់ឱ្យរដ្ឋាភិបាលកម្ពុជា និងអ៊ីតាលីផ្អាកការបើកដំណើរការឡើងវិញនៃការសុំកូនឆ្លងប្រទេស



*ស្ត្រីម្នាក់កំពុងពកូននៅមុខព្រះបរមរាជវាំងក្នុងទីក្រុងភ្នំពេញកាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣។ ខេមបូចា/ ព្រីង សំរាំង*

ក្រុមអង្គការសង្គមស៊ីវិលតាមរយៈសេចក្តីថ្លែងការណ៍រួមរបស់ខ្លួនចេញកាលពីថ្ងៃពុធថាការបើកឡើងវិញឱ្យមានការសុំកូនឆ្លងប្រទេសនឹងធ្វើឱ្យកុមារកម្ពុជា និងគ្រួសាររបស់ពួកគេជួបហានិភ័យ ហើយស្ថាប័នទាំងនេះបានជំរុញឱ្យរដ្ឋាភិបាលកម្ពុជាបញ្ឈប់ដំណើរការនេះ។

កម្ពុជាបានផ្អាកការសុំកូនឆ្លងប្រទេសក្នុងឆ្នាំ២០០៩ ក្រោយពីមានសេចក្តីរាយការណ៍ជាច្រើនអំពីអំពើខុសក្រមសីលធម៌ជាច្រើនទាក់ទង

នឹងការសុំកូន។ ប្រទេសជាច្រើនក៏បានហាមឃាត់ការសុំកូនពីកម្ពុជាដែរក្នុងអំឡុងទសវត្សរ៍ឆ្នាំ២០០០។ ប៉ុន្តែនៅប៉ុន្មានខែចុងក្រោយនេះ ប្រទេសអ៊ីតាលី និងកម្ពុជាបានចាប់ផ្តើមបោះជំហានទៅរកការបើកឱ្យមានការសុំកូនពីកម្ពុជាឡើងវិញ។

សង្គមស៊ីវិលធ្វើការផ្នែកសិទ្ធិមនុស្សមានដូចជាមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា អង្គការអាដហុក និងលីកាដូ ព្រមជាមួយនឹងបណ្តុំអង្គការអន្តរជាតិ Intercountry Adoptee Voices បានចេញសេចក្តីថ្លែងការណ៍រួមមួយដោយបានស្នើឱ្យរដ្ឋាភិបាលកម្ពុជា និងអ៊ីតាលី ផ្អាកជាបន្ទាន់នូវសកម្មភាពនាំឱ្យមានការបើកឡើងវិញនូវការសុំកូនឆ្លងប្រទេសនេះ។

របាយការណ៍របស់អង្គការលីកាដូ ឆ្នាំ២០១៨ បានបង្ហាញថា កុមារកម្ពុជាដែលត្រូវគេសុំយក ទៅចិញ្ចឹមនៅក្រៅប្រទេសរវាងទសវត្សរ៍ឆ្នាំ១៩៨០ ដល់ឆ្នាំ២០០៩ មានជាច្រើនពាន់នាក់ ប៉ុន្តែថាក្មេងជាច្រើននាក់ក្នុងចំណោមនោះមិនមែនជាក្មេងកំព្រានោះទេ។ អ្វីដែលគេរកឃើញគឺថាក្មេងៗទាំងនោះត្រូវឪពុកម្តាយយកទៅដាក់នៅមណ្ឌលកុមារកំព្រា ដោយសារតែពួកគេមានជីវភាពក្រីក្រ។

នាយិកាអង្គការលីកាដូ លោកស្រី ណាលី ពីឡូក មានប្រសាសន៍ថា៖ *«ការបើកឱ្យមានដំណើរការសុំកូនឆ្លងប្រទេសជាថ្មីនឹងធ្វើឱ្យក្មេងកម្ពុជា*

*និងគ្រួសារពួកគេប្រឈមហានិភ័យ។ ការសុំកូនពីកម្ពុជាពីទសវត្សរ៍ឆ្នាំ ១៩៩០ ដល់ទសវត្សរ៍ឆ្នាំ២០០០ បានបង្ហាញឱ្យឃើញពីការបោកប្រាស់ ពុករលួយ និងការបង្ខិតបង្ខំ»*។

លោកស្រីឱ្យដឹងទៀតថា ការបំពានសិទ្ធិមនុស្ស *«គួរឱ្យរន្ធត់»* នេះបានជះផលអវិជ្ជមានជាខ្លាំង។ លោកស្រីបន្ថែមថា ទាំងកម្ពុជា និងអ៊ីតាលីមិនបានយកចិត្តទុកដាក់លើការឈឺចាប់ និងទុក្ខវេទនាដែលបង្កឡើងដោយការសុំកូនដោយខុសច្បាប់ និងមិនទាន់បានផ្តល់ជាជំនួយដល់ក្មេងៗទាំងនោះ និងក្រុមគ្រួសារដែលបានបែកបាក់គ្នានោះទេ។

លោកស្រីលើកឡើងថា៖ *«អ៊ីតាលីត្រូវទទួលស្គាល់ការពិតពីស្ថានភាពនៅកម្ពុជា។ ច្បាប់ថ្មីមិនបានផ្តល់ការធានាការពារប្រឆាំងនឹងការឆបោកដែលកើតមានជាប្រព័ន្ធពីអតីតកាលលើការសុំកូននោះទេ ជាពិសេសបានធ្វើឱ្យឃើញថា កម្ពុជាមិនមានឆន្ទៈក្នុងការបង្ហាញការទទួលខុសត្រូវលើការរំលោភបំពានកាលពីអតីតកាលកន្លងមក»*។ លោកស្រីបន្ថែមទៀតថា៖ *«កម្ពុជាត្រូវយកចិត្តទុកដាក់លើកុមាររបស់ខ្លួនឱ្យបានច្រើនជាងនេះពេលនៅក្នុងប្រទេស មុននឹងអនុញ្ញាតឱ្យមានលទ្ធភាពក្នុងការបញ្ជូនពួកគេចេញទៅបរទេស»*។

កាលពីខែឧសភា ឆ្នាំ២០២៣ ក្រសួងសង្គមកិច្ចកម្ពុជាបានជួបជាមួយប្រតិភូមកពីគណៈកម្មការធិការសម្រាប់ការសុំកូនឆ្លងប្រទេសរបស់អ៊ីតាលី។

ភ្នាក់ងារសុំកូនអ៊ីតាលីចំនួនបីត្រូវបានអនុញ្ញាតឱ្យបើកដំណើរការនៅកម្ពុជា និងមានភ្នាក់ងារបីបន្ថែមទៀតកំពុងព្យួរអាជ្ញាបណ្ណនៅឡើយ។ នេះបើតាមគណៈកម្មាធិការរបស់អ៊ីតាលី។ នៅចុងឆ្នាំនេះ អាចមានក្មេងចំនួនរហូតដល់ពីរនាក់ពីភ្នាក់ងារមួយៗអាចនឹងត្រូវផ្គូផ្គងត្រូវនឹងគ្រួសារនៅអ៊ីតាលី។

បើតាមវេបសាយរបស់គណៈកម្មាធិការអ៊ីតាលី គណៈកម្មាធិការខ្លួនឯងរំពឹងថានឹងបានទទួលបញ្ជីឈ្មោះកុមារដែលគ្រប់លក្ខខណ្ឌសម្រាប់សុំទៅចិញ្ចឹមបាន ពីរដ្ឋាភិបាលកម្ពុជាក្នុងខែមិថុនា ឆ្នាំ២០២៣ នេះ។ ប្រភពដដែលបន្តថា បច្ចុប្បន្នមាន *«នីតិវិធីមិនទាន់បានសម្រេច»* ចំនួនប្រាំបួនសម្រាប់ការសុំកូនពីកម្ពុជាទៅអ៊ីតាលី។

មន្ត្រីក្រសួងសង្គមកិច្ចត្រូវបានអញ្ជើញឱ្យទៅប្រទេសអ៊ីតាលីនៅឆ្នាំ២០២៤ ដើម្បីទៅពិនិត្យតាមដានលើកុមារដែលត្រូវបានសុំយកទៅចិញ្ចឹម។

ស្ថានទូតអ៊ីតាលីមិនបានឆ្លើយតបទៅនឹងការសុំធ្វើអត្ថាធិប្បាយលើរឿងនេះទេកាលពីថ្ងៃចន្ទ។

ទាក់ទងតាមទូរស័ព្ទកាលពីថ្ងៃពុធ លោក តូច ចាន់នី អ្នកនាំពាក្យក្រសួងសង្គមកិច្ចមានប្រសាសន៍ថា លោកមិនទាន់បានអានសេចក្ដីថ្លែងការណ៍រួមរបស់អង្គការសង្គមស៊ីវិលនោះនៅឡើយ ដែលថាហេតុនេះលោកមិនអាចអត្ថាធិប្បាយបានទេ។

លោក តូច ចាន់នី ឱ្យដឹងដែរថា រដ្ឋាភិបាលកម្ពុជាបើកឱ្យដំណើរការសុំកូនឆ្លងប្រទេសឡើងវិញក៏ព្រោះថាកម្ពុជាថ្មីៗនេះបានធ្វើសេចក្ដីព្រាងច្បាប់ដែលមានការគាំពារគ្រប់គ្រាន់ពេលបញ្ជូនកុមារទៅបរទេស។ លោកអះអាងថា ពីមុនកម្ពុជាបានផ្អាកដំណើរការនេះ ក៏ដោយសារតែប្រទេសនៅពេលនោះមិនទាន់មានច្បាប់សុំកូនប្រកបដោយប្រសិទ្ធភាព ឬមិនទាន់បានធ្វើការកែប្រែឱ្យបានល្អ។

លោកបញ្ជាក់ថា៖ «ការបើកឡើងវិញ [ការសុំកូនឆ្លងប្រទេស] គឺព្រោះថាយើងមានច្បាប់។ ពីមុនយើងមិនមានច្បាប់ស្ដីពីសុំកូន ហើយច្បាប់ខ្លះមិនអាចអនុវត្តបាន»។

លោក ចាន់នី បន្តថា ការសុំកូនឆ្លងប្រទេសនេះមានក្នុងប្រទេសជាច្រើនមិនមែនមានតែកម្ពុជាទេ។

លោកថ្លែងថា៖ *«[ប្រទេស] នីមួយៗមានភ្នាក់ងាររបស់ពួកគេ ហើយថាភ្នាក់ងារនោះត្រូវមក និងចរចាកិច្ចសន្យាជាមួយយើងដោយផ្អែកតាម*

*ច្បាប់ ហើយនៅមានការពិភាក្សាខ្លះទៀតត្រូវធ្វើឡើងអំពីឯកសារដោយផ្អែកទៅតាមច្បាប់*»។

លោក ចាន់នី បន្ថែមទៀតថា ការបើកឱ្យមានការសុំកូនជាថ្មីរបស់កម្ពុជានេះក៏មានរួមបញ្ចូលសហរដ្ឋអាមេរិកផងដែរ។

ស្ថានទូតអាមេរិកមិនបានឆ្លើយតបសំណួររបស់ខេមបូចាដែលផ្ញើតាមអ៊ីម៉ែល ដោយសួរថាតើសហរដ្ឋអាមេរិកបានបើកឱ្យមានការសុំកូនឆ្លងប្រទេសជាមួយកម្ពុជាឬយ៉ាងណា។ ក្នុងសេចក្ដីថ្លែងការណ៍របស់ខ្លួនក្នុងឆ្នាំ២០២១ ក្រសួងការបរទេសអាមេរិកបានថ្លែងថា៖ *«ពេលនេះមិនទាន់មានព័ត៌មានលម្អិតថាត្រូវធ្វើដូចម្ដេច ឬពេលណាដែលអាចបើកឱ្យដំណើរការឡើងវិញនូវការសុំកូនឆ្លងប្រទេសនេះទេ*»។

អ្នកនាំពាក្យគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា លោក កត្តា អ៊ន មានប្រសាសន៍ថា ការបើកឱ្យមានការសុំកូនឡើងវិញមិនបំពានទៅនឹងសិទ្ធិកុមារនោះទេ ដោយថាកម្ពុជាមានច្បាប់តឹងរឹងស្ដីពីការការពារសិទ្ធិរបស់កុមារដែលត្រូវគេសុំយកទៅចិញ្ចឹម។ លោកថាការសុំកូនយកទៅចិញ្ចឹម គឺជាសកម្មភាពមនុស្សធម៌មួយដែរ។

លោកបន្ថែមថា បើសិនជាអង្គការសង្គមស៊ីវិលរកឃើញនូវភាពមិនប្រក្រតី ឬភស្តុតាងណាមួយលើការរំលោភបំពាន ឬជួញដូរកុមារ ស្ថា

ប័នទាំងនោះគួរតែធ្វើការជាមួយអាជ្ញាធរជាតិ និងអន្តរជាតិទប់ស្កាត់បញ្ហាទាំងនេះ។

លោកបន្តថា៖ *«បើសិនជាយើងនៅតែនិយាយដោយមិនមានភស្តុតាងច្បាស់លាស់ មិនមានសក្ខីកម្មច្បាស់លាស់ វានឹងបំពានសិទ្ធិរបស់កុមារទៅវិញ ពីព្រោះថាប្រទេសនៅជុំវិញពិភពលោក ការសុំក្មេងទៅចិញ្ចឹម គឺជាការសង្គ្រោះកុមារ»*។

ជាការឆ្លើយតបទៅនឹងសំណួរទៅកាន់លោកស្រី Roueida El Hage ប្រធានការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិនៅកម្ពុជា ហៅកាត់ថា OHCHR អ្នកនាំពាក្យស្ថាប័ននេះបានឱ្យដឹងកាលពីថ្ងៃអង្គារថា OHCHR មិនមាន *«ភាតព្វកិច្ចជាក់លាក់»* លើកិច្ចការកុមារនោះទេ ហើយថាអង្គការយូនីសេហ្វជាអ្នកធ្វើការលើកិច្ចការនេះ។

អ្នកនាំពាក្យអង្គការយូនីសេហ្វ Hadrien Bonnaud មិនបានឆ្លើយតបទៅនឹងសំណួរតាមអ៊ីម៉ែលរបស់ខេមបូចាទេ កាលពីថ្ងៃចន្ទ។

រវាងឆ្នាំ១៩៩៨ ដល់ឆ្នាំ២០១១ កុមារកម្ពុជាចំនួន ៣ ៦៩៦នាក់ត្រូវបានជនបរទេសសុំយកទៅចិញ្ចឹម។ នេះបើតាមវេបសាយរបស់ OHCHR។ តាំងពីឆ្នាំ២០១៧ គ្រួសារចំនួនប្រាំមួយបានទាក់ទងមកអង្គការ លីកាដូ

ដើម្បីស្វែងរកព័ត៌មានបន្ថែមអំពីកុមារចំនួន១៥នាក់ ដែលគេសង្ស័យថាត្រូវបានឆបោកសុំកូនពីកម្ពុជាក្នុងកំឡុងឆ្នាំ២០០០។

គម្រោងយុត្តិធម៌ពិភពលោកឆ្នាំ២០២២ ស្តីពីសន្ទស្សន៍នីតិរដ្ឋនៅកម្ពុជាបានដាក់ប្រទេសកម្ពុជានៅលេខរៀងទីពីរពីបាតតារាងក្នុងចំណោមប្រទេសនានាលើសកលលោក ខណៈដែលអង្គការតម្លាភាពអន្តរជាតិសម្រាប់សន្ទស្សន៍នៃអំពើពុករលួយសម្រាប់ឆ្នាំ២០២២ បានដាក់ចំណាត់ថ្នាក់កម្ពុជានៅលេខរៀងទី១៥ គិតពីក្រោមមក ក្នុងចំណោមប្រទេសនានាលើពិភពលោក ៕